# ពោធិសត្តកថា

របស់បណ្ឌិតមហាឈឹម-ស៊ុម អតីតសាស្ត្រាចារ្យ

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

ក្រុងភ្នំពេញ

ដកស្រង់ចេញពីពន្លឺពុទ្ធចក្រ ទស្សនាវដ្តីប្រចាំត្រីមាស

នៃ

ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ

លេខ១២៣ ខែកក្កដា-សីហា-កញ្ញា

ព.ស.២៥០៩ គ.ស.១៩៦៦

***

ពាក្យថា ពោធិសត្ត ជាភាសាបាលី (សំ.ពោធិសត្វ)។ គេអានតាមលំនាំបាលីថា ពោធិស័តតៈ, អានតាមលំនាំខ្មែរថា ពោធិស័ត។ ពាក្យនេះមកអំពី ពុធ-ធាតុ ប្រែថា ដឹងឬត្រាស់ឬក៏ត្រាស់ដឹងឬក៏ប្រាជ្ញាជាគ្រឿងត្រាស់ដឹង។ ករណនាមៈ ពោធិ; ការកនាមៈ ពុទ្ធ; កិរិយាៈ ពុជ្ឈតិ។ សត្ត មកអំពី សជ-ធាតុ ប្រែថា ជាប់ឬជំពាក់។ ករណនាមៈ សជ្ជន; ការកនាមៈ សត្ត; កិរិយាៈ សជ្ជតិ។

ពោធិ+សត្ត>ពោធិសត្ត ប្រែថា បុគ្គលអ្នកមានចិត្តជាប់ក្នុងការត្រាស់ដឹងឬ បុគ្គលអ្នកមានចិត្តជាប់ក្នុងប្រាជ្ញាជាគ្រឿងត្រាស់ដឹង។

# អធិប្បាយថា

ព្រះពុទ្ធបានឃើញច្បាស់នូវកំណើតរបស់ព្រះអង្គនិងរបស់ពួកជនដទៃ ដែលធ្លាប់កើតក្នុងជាតិមុនៗ រាប់សែនអសង្ខេយ្យកប្ប ដោយប្រាជ្ញាណា, ប្រាជ្ញានោះឈ្មោះ បុព្វេនិវាសានុស្សតិញ្ញាណ។ ព្រះពុទ្ធបានឃើញច្បាស់នូវកំណើតនៃពួកសត្វ គឺមនុស្សនិងតិរច្ឆានជាដើម ដែលស្លាប់ទៅកើតជាអ្វីៗ ដោយប្រាជ្ញាណា, ប្រាជ្ញានោះឈ្មោះ ចុតូបបាតញ្ញាណ។ ព្រះពុទ្ធញ៉ាំងអាសវក្កិលេស គឺអវិជ្ជានិងតណ្ហាជាដើមឲ្យអស់ទៅ ដោយប្រាជ្ញាណា, ប្រាជ្ញានោះឈ្មោះ អាសវក្ខយញ្ញាណ។

មួយទៀត ពាក្យថា ព្រះពុទ្ធបានត្រាស់ គឺព្រះពុទ្ធបាននូវប្រាជ្ញាញាណទាំង៣នេះ។ ព្រះពុទ្ធរកឃើញនូវអរិយសច្ចទាំង៤និងព្រះនិព្វាន ដោយព្រះប្រាជ្ញាញាណទាំង៣នេះ។ ប្រាជ្ញាញាណទាំង៣នេះឯង ដែលហៅថា ពោធិ។ បុគ្គលណាមានចិត្តជាប់ក្នុងពោធិ គឺថាក្នុងជាតិណាក្តី ក្នុងពេលណាក្តី តែងតែមានចិត្តចង់បាននូវពោធិនេះ, បុគ្គលនោះឈ្មោះថា ពោធិសត្ត។ បើនិយាយឲ្យងាយស្តាប់ថាៈ អ្នកណាចង់ត្រាស់ជាព្រះពុទ្ធ គឺថាចង់ដឹងឲ្យដល់ឋានៈជាព្រះពុទ្ធ, អ្នកនោះឈ្មោះថា ពោធិសត្ត។ ប៉ុន្តែពុំមែនគ្រាន់តែចង់មួយដងមួយ

កាល ហើយភ្លេចបាត់ទៅទេ, លុះតែចង់ហើយទ្រាំនៅស្ងៀមពុំបាន ហ៊ាន បំពេញបារមីទាំង១០ប្រការ[១]ឬទាំង៣០ប្រការ ប្តូរទ្រព្យសម្បត្តិ ប្តូរប្រពន្ធកូន ប្តូរអាយុជីវិតក្នុងការបំពេញបារមី ហើយមិនតែមួយដងមួយកាលទេ, ច្រើន ដងណាស់អស់អសង្ខេយ្យជាតិ អសង្ខេយ្យកប្ប, អ្នកនោះទើបឈ្មោះថា ពោធិសត្ត។

ត្រង់ពុទ្ធាទីនមកិនីហារកថា ក្នុងគម្ពីរសារត្ថសង្គហៈ (បាលី) មានសេច ក្តីចែងអំពីពោធិសត្វយ៉ាងពិស្តារ។ ខ្ញុំស្រង់ន័យខ្លះមកដាក់ក្នុងទីនេះ ដោយ សង្ខេបដូចតទៅៈ

## ព្រះពុទ្ធ៣ជំពូក

ព្រះពុទ្ធជាម្ចាស់ដែលត្រាស់ក្នុងលោក មានចំនួនច្រើនគគោករាប់ក្នុង ទីនេះពុំបាន បុរាណហៅថា ព្រះពុទ្ធទាំងអម្បាលខ្សាច់។ ប៉ុន្តែបើរាប់តាម ប្រភេទដែលផ្សេងគ្នា មានតែ៣ជំពូកគឺ ព្រះពុទ្ធបញ្ញាធិក មានប្រាជ្ញាដ៏លើស លុបជាងសទ្ធានិងវីរិយៈ១, ព្រះពុទ្ធសទ្ធាធិក មានសទ្ធាដ៏លើសលុបជាងប្រាជ្ញា និងវីរិយៈ១, ព្រះពុទ្ធវីរិយាធិក មានព្យាយាមដ៏លើសលុបជាងប្រាជ្ញានិង សទ្ធា១។

---

**១-ទានបារមី, សីលបារមី, នេក្ខម្មបារមី, បញ្ញាបារមី, វីរិយបារមី, ខន្តិបារមី, សច្ចបារមី, អធិដ្ឋាន បារមី, មេត្តាបារមីនិងឧបេក្ខាបារមី។**

# ព្រះពោធិសត្ត៣ជំពូក

ព្រះពុទ្ធបានជាមានភេទប្លែកគ្នាជា៣បែបដូច្នេះ ព្រោះកាលដែលនៅជាពោធិសត្វនៅឡើយ បំពេញបារមីដោយកិរិយាប្លែកគ្នាជា៣បែបដែរ គឺព្រះពោធិសត្វដែលប្រើប្រាជ្ញាខ្លាំង មានប្រាជ្ញាច្រើន ពុំសូវមានជំនឿ មានព្យាយាមមធ្យម, នោះលោកហៅថា បញ្ញាធិកពោធិសត្វ១។ ព្រះពោធិសត្វដែលប្រើសទ្ធាខ្លាំង មានជំនឿច្រើន មានប្រាជ្ញានិងវីរិយៈមធ្យម, នោះលោកហៅថា សទ្ធាធិកពោធិសត្វ១។ ព្រះពោធិសត្វដែលប្រើព្យាយាមខ្លាំង មានសេចក្តីព្យាយាមច្រើន មានប្រាជ្ញានិងសទ្ធាមធ្យម, នោះលោកហៅថា វីរិយាធិកពោធិសត្វ១។

# កំណត់កាលនៃការបំពេញបារមីនៃពោធិសត្វ

ពីត្រឹមកាលដែលពោធិសត្វទាំងឡាយ បានទំនាយអំពីព្រះពុទ្ធអង្គណាមួយទាយថា បុគ្គលនេះនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះមកនោះ ព្រះបញ្ញាធិកពោធិសត្វ បំពេញបារមីទាំង១០អស់វេលា៤អសង្ខេយ្យនិង១សែនកប្បទៀត ទើបបានត្រាស់ជាព្រះពុទ្ធបញ្ញាធិក។ ព្រះសទ្ធាធិកពោធិសត្វ បំពេញបារមីទាំង១០ អស់វេលា៨អសង្ខេយ្យនិង១សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធសទ្ធាធិក។ ព្រះវីរិយាធិកពោធិសត្វ បំពេញបារមីទាំង១០ អស់វេលា១៦អសង្ខេយ្យនិង១សែនកប្បទៀត ទើបបានត្រាស់ជាព្រះពុទ្ធវីរិយាធិក។ ការ

បំពេញបារមីនៃពោធិសត្វទាំង៣ប្រភេទនេះ មុនពេលដែលបានពុទ្ធទំនាយឯណោះ ក៏មានអស់វេលាច្រើនកប្បណាស់ដែរ, តែយើងពុំអាចពោលក្នុងទីនេះបាន។

## ព្រះពោធិសត្វ២ជំពូក

ព្រះពោធិសត្វទាំង៣ប្រភេទនេះ លោករួបរួមហៅឲ្យខ្លីមកមានតែ២គឺ អនិយតពោធិសត្វ១ និយតពោធិសត្វ១។ ពោធិសត្វដែលបំពេញបារមីទាំង ១០ អស់កាលដ៏យូរអង្វែងដែរហើយ ប៉ុន្តែពុំទាន់បានពុទ្ធព្យាករណ៍ គឺព្រះពុទ្ធអង្គណាមួយពុំទាន់បានទាយឲ្យនៅឡើយ, នោះលោកហៅថា អនិយតពោធិសត្វ ព្រោះជាពោធិសត្វពុំទាន់ប្រាកដជាបានត្រាស់ឬពុំបានត្រាស់ទេ, ដ្បិតថា អនិយតពោធិសត្វនេះ ជួនកាលបានជួបនឹងព្រះពុទ្ធអង្គណាមួយបានស្តាប់ធម៌ព្រះអង្គហើយ ស្រាប់តែសម្រេចព្រះអរហត្ត បានឋានៈជាព្រះអរហន្តចូលនិព្វានទៅក៏មាន។ ព្រះពោធិសត្វដែលបំពេញបារមីទាំង១០អស់កាលដ៏អង្វែងមកហើយ, គ្រាបានជួបនឹងព្រះពុទ្ធអង្គណាមួយ បានពុទ្ធព្យាករណ៍ ដែលព្រះពុទ្ធអង្គនោះទាយឲ្យហើយ តពីនោះមក លោកហៅថា និយតពោធិសត្វ ព្រោះព្រះពោធិសត្វអង្គនេះទៀងតែបានត្រាស់ជាព្រះពុទ្ធ។

អនិយតពោធិសត្វ អ្នកប្រាជ្ញច្រើនហៅថា ពោធិសត្វៗ ទទេៗឬហៅថា វីរបុរស។ និយតពោធិសត្វ អ្នកប្រាជ្ញច្រើនហៅថា បរមពោធិសត្វឬមហា

សត្តឬក៏មហាបុរស ប្រែថា សត្វធំឬបុរសធំ គឺធំដោយគុណ មានទានឬក៏សីលនិងនេក្ខម្មជាដើម។

## និយតពោធិសត្ត៣ជំពូក

បណ្ដាព្រះបញ្ញាធិក សទ្ធាធិក វីរិយាធិក ពោធិសត្វទាំង៣ ដូចបានពោលមកហើយនោះ, ក្នុងកាលមុននឹងបានព្យាករណ៍ឲ្យជានិយតពោធិសត្វនោះ មួយៗមានព្រះនាមបីៗផ្សេងគ្នា មានគុណធម៌ គឺបញ្ញាខ្លាំងក្លាឬមធ្យមឬក៏ទន់ខ្សោយ។ ព្រះពោធិសត្វដែលបំពេញបារមីអស់កាលដ៏អង្វែងហើយ មានប្រាជ្ញាខ្លាំងក្លា ឈ្មោះថា ឧគ្ឃដិតញ្ញូពោធិសត្វ១, ព្រះពោធិសត្វដែលបំពេញបារមីអស់កាលដ៏អង្វែងហើយ មានប្រាជ្ញាមធ្យម ឈ្មោះថា វិបចិតញ្ញូពោធិសត្វ១, ព្រះពោធិសត្វដែលបំពេញបារមីអស់កាលដ៏អង្វែងហើយដែរ តែមានប្រាជ្ញាទន់ខ្សោយ ឈ្មោះថា នេយ្យ-ពោធិសត្វ១។ ពោធិសត្វទាំង៣ជំពូកនេះ សុទ្ធតែបានបំពេញបារមីក្រាស់ក្រែលមកស្រាប់ ប៉ុន្តែពុំបានពុទ្ធទំនាយ។ ក្នុងគ្រាដែលលោកប្រកបដោយអដ្ឋធម្មសមោធាន ស្រាប់តែបានជួបនឹងព្រះពុទ្ធបានពុទ្ធទំនាយ បានស្ដាប់ធម៌ព្រះពុទ្ធ, បើលោកចង់បានព្រះអរហត្តក្នុងជាតិនោះ ព្រះឧគ្ឃដិតញ្ញូពោធិសត្វ ស្ដាប់ធម៌ទេសនាគាថា៤បាទ ក៏អាចសម្រេចព្រះអរហត្តប្រកបដោយបដិសម្ភិទាញាណ៦ ក្នុងកាលមិនទាន់ចប់គាថាទី៣។ ព្រះវិបចិតញ្ញូពោធិសត្វ អាចសម្រេចព្រះអរហត្តព្រមដោយអភិញ្ញា

៦ ក្នុងកាលមិនទាន់ចប់បាទទី៤នៃព្រះគាថា។ ព្រះនេយ្យពោធិសត្វ អាចសម្រេចព្រះអរហត្តព្រមដោយអភិញ្ញា៦ ក្នុងកាលចប់ព្រះគាថាទាំង៤បាទស្រេចហើយ ព្រះពុទ្ធទ្រង់វែកញែកចែកអត្ថឲ្យពិស្តារតទៅទៀត។

ព្រះពោធិសត្វទាំង៣ជំពូកនេះ បើពុំព្រមទទួលព្រះអរហត្តផលជាសាវកពោធិញ្ញាណក្នុងជាតិនេះទេ, ព្រះពោធិសត្វនោះឯងបានឈ្មោះថា និយតពោធិសត្វ នឹងបានត្រាស់ជាព្រះពុទ្ធបញ្ញាធិកឬសទ្ធាធិកឬវីរិយាធិក តទៅក្នុងអនាគតពិតប្រាកដ។

# អដ្ឋធម្មសមោធាន

ព្រះពោធិសត្វទាំងឡាយ ដែលគួរឲ្យព្រះពុទ្ធអង្គណាមួយទាយ ដើម្បីឲ្យបានឋានៈជានិយតពោធិសត្វ ប្រាកដជានឹងបានត្រាស់ក្នុងអនាគតមែននោះ លុះត្រាតែប្រកបដោយប្រជុំធម៌៨ប្រការ ដែលហៅថា អដ្ឋធម្មសមោធាន គឺៈ

**១–មនុស្សត្តំ** ភាពនៃខ្លួនជាមនុស្ស គឺក្នុងគ្រាដែលជួបនឹងព្រះពុទ្ធនោះ តួអង្គពោធិសត្វ ពុំមែនជាទេវតាឬព្រហ្មទេ។

**១–លិង្គសម្បត្តិ** បរិបូណ៌ដោយភេទជាបុរស។

**៣–ហេតុ** មានឧបនិស្ស័យនៃព្រះអរហត្តគ្រប់គ្រាន់ គឺធ្លាប់បានបំពេញបារមីទាំង១០សព្វគ្រប់ល្មមទទួលអរហត្តគុណបាន។

***៤–សត្ថារទស្សនំ***[១] ការបានជួបនឹងព្រះពុទ្ធជាម្ចាស់។

***៥–បព្វជ្ជា*** ការបួស គឺថាក្នុងគ្រានោះតួអង្គពោធិសត្វ ជាអ្នកបួសស្រាប់។

***៦–គុណសម្បត្តិ*** បរិបូណ៌ដោយគុណធម៌ គឺថាក្នុងគ្រានោះ មិនត្រឹមតែជាអ្នកបួសប៉ុណ្ណោះ ថែមទាំងបាននូវគុណសម្បត្តិ មានឈាននិងអភិញ្ញាទៀតផង។

***៧–អធិការោ*** ការធ្វើនូវប្រយោជន៍ទូទៅ គឺថាក្នុងជាតិនោះ បានឲ្យទានឥតមានការស្តាយស្រណោះ សូម្បីជីវិតរបស់ខ្លួន ក៏ហ៊ានបរិច្ចាគដែរ បើមានគេសុំ។

*៨–ឆន្ទតា សេចក្តីប្រាថ្នាដ៏ក្លាហាន ចំពោះពោធិញ្ញាណ។*

## អភព្វដ្ឋាន១៨

*កន្លែងមិនសមគួរ គឺកន្លែងដែលអ្នកមានអភិនីហារចាស់ក្លា មិនគួរកើត ហៅថា អភព្វដ្ឋាន មាន១៨។ ព្រះនិយតពោធិសត្វ ពុំដែលកើតក្នុងកន្លែងទាំង១៨នោះឡើយ គឺៈ*

*១–ព្រះអង្គមិនកើតជាមនុស្សត្រចៀកថ្លង់ ភ្នែកខ្វាក់ពីកំណើតឡើយ*

*២–មិនកើតជាមនុស្សខ្វិន មនុស្សគ មនុស្សឆ្កួត*

---

*១-សត្ថុទស្សនំ?*

៣–មិនកើតជាមនុស្សលេលា

៤–មិនកើតជាកូនទាសី

៥–មិនជានិយតមិច្ឆាទិដ្ឋិជន គឺមិនជាមនុស្សយល់ខុសកែមិនឡើងឡើយ

៦–មិនកើតជាស្ត្រី

៧–មិនធ្វើអនន្តរិយកម្ម

៨–មិនកើតរោគឃ្លង់

៩–កើតជាតិតិរច្ឆាន មិនជាសត្វតូចជាងចាប មិនជាសត្វធំជាងដំរី

១០–មិនកើតជាខុប្បិបាសិកប្រេត (ប្រេតស្រេកឃ្លានខ្លាំង)

១១–មិនកើតជានិជ្ឈាមកណ្ហិកប្រេត (ប្រេតដែលមានរាងកាយខ្មៅមានភ្លើងឆេះ

១២–មិនកើតជាកាឡសញ្ជិកាសូរ (អសុរមានរាងកាយខ្ពស់សម្បុរខ្មៅរូបធំសម្លឹមគួរស្ញប់ស្ញែង)

១៣–មិនកើតក្នុងនរកអវិចី

១៤–មិនកើតក្នុងនរកលោកន្តរ

១៥–មិនកើតជាទេវបុត្តមារក្នុងឆកាមាវចរសួគ៌

១៦–មិនកើតជាអសញ្ញីព្រហ្ម

១៧–មិនកើតជាអរូបព្រហ្ម

១៨–មិនកើតក្នុងចក្រវាឡដទៃផ្សេងពីចក្រវាឡនេះ។

## ពុទ្ធភូមិធម៌៤

ធម៌ជាជាន់ ជាថ្នាក់សម្រាប់និយតពោធិសត្វប្រព្រឹត្តដើម្បីឡើងទៅកាន់ឋានៈជាព្រះពុទ្ធ ហៅថា ពុទ្ធភូមិធម៌ មាន៤យ៉ាងគឺៈ

**១–ឧស្សាហោ** សេចក្តីសង្វាតខ្មីឃ្មាតខ្មះខ្នែងប្រឹងប្រែងក្នុងករណីយកិច្ចដ៏ល្អៗ ដែលហៅថា កុសលកម្ម។

**២–ឧម្មង្គោ** ផ្លូវលើ គឺប្រាជ្ញាក្លៀវក្លាវាងវៃក្នុងករណីយដែលត្រូវធ្វើ (ធ្វើការអ្វីមិនដែលខូច មិនឲ្យមានអន្តរាយ)។

**៣–អវត្ថានំ** ការតាំងចិត្តសង្កត់ជាប់យ៉ាងមាំក្នុងករណីយល្អៗ ដែលហៅថា កុសលកម្ម បើមិនទាន់សម្រេចក៏មិនលែងធ្វើ។

**៤–ហិតចរិយា** ការប្រព្រឹត្តធ្វើត្រឹមតែអំពើមានប្រយោជន៍ គឺការងារដែលជាប្រយោជន៍ដល់ខ្លួនឬជាប្រយោជន៍ដល់ជនដទៃឬក៏ជាប្រយោជន៍ដល់ខ្លួនផង ដល់ជនដទៃផង។

# អធ្យាស្រ័យ៦

ការដេកសង្កត់នៃចិត្ត គឺចិត្តដែលដួលដេកផ្តេកផ្តិតជាប់ស្អិតក្នុងអ្វីមួយនោះហៅថា អធ្យាស្រ័យ។ ព្រះនិយតពោធិសត្វ មានអធ្យាស្រ័យ៦ ជាប់ជានិច្ចរាល់ជាតិគឺៈ

**១–អលោភជ្ឈាសយោ** អធ្យាស្រ័យមិនលោភ គឺព្រះទ័យព្រះអង្គគាប់នឹងការមិនជាប់ជំពាក់ដោយវត្ថុផ្សេងៗ គាប់នឹងការមិនចង់បានតែម្នាក់ឯង តែងចែកការបានឲ្យអ្នដទៃផង, គ្រាបានហើយ មិនឱបក្រសោបទុកឡើយ តែងចំណាយក្នុងការមានប្រយោជន៍តាមការលៃលក។

**២–អទោសជ្ឈាសយោ** អធ្យាស្រ័យមិនខឹងមិនប្រទូស្តតប គឺព្រះទ័យព្រះអង្គគាប់នឹងការមិនប្រទូស្ត មានខន្តីទប់ជានិច្ច, ភ្លើងកំហឹងដែលកើតឡើងព្រះអង្គតែងលត់បានដោយទឹក គឺខន្តីនិងមេត្តា។

**៣–អមោហជ្ឈាសយោ** អធ្យាស្រ័យមិនវង្វេងភ័ន្តច្រឡំ គឺព្រះទ័យព្រះអង្គក្នុងកិច្ចពិចារណានូវគុណនិងទោស បុណ្យនិងបាបនិងការចម្រើននូវអប្បមាទធម៌។

**៤–នេក្ខម្មជ្ឈាសយោ** អធ្យាស្រ័យក្នុងការចេញសាង គឺព្រះទ័យព្រះអង្គគាប់ក្នុងការចេញទ្រង់បព្វជ្ជា (ចេញបួស)។

**៥–បវិវេកជ្ឈាសយោ** អធ្យាស្រ័យក្នុងការស្ងប់ស្ងាត់ គឺព្រះទ័យព្រះអង្គ

គាប់ក្នុងការចេញចាកពួកគណៈ ហើយនៅក្នុងការស្ងប់ស្ងាត់។

**៦–និស្សរណជ្ឈាសយោ** អធ្យាស្រ័យក្នុងការរលាស់ខ្លួន គឺព្រះទ័យព្រះអង្គគាប់ក្នុងការរើខ្លួនចេញចាកភព មិនត្រេកអរក្នុងការស្លាប់កើតៗ វិលវល់ក្នុងភព។

## បរិយោសានកថា

ពោធិសត្តកថា ការពោលអំពីពោធិសត្វដោយសេចក្ដីសង្ខេបខ្លីមកប៉ុណ្ណេះ ដើម្បីជាគំរូនៃខប្រតិបត្តិ។ សាធុជនអ្នកបានអានបានស្ដាប់នូវកថានេះ គួរពិចារណាឲ្យយល់ច្បាស់នូវគោលការណ៍នៃសេចក្ដីប្រតិបត្តិរបស់ព្រះពោធិសត្វ ដែលលោកធ្លាប់ប្រតិបត្តិមកហើយ លោកបានត្រាស់ជាព្រះពុទ្ធនាំសត្វទៅកាន់ព្រះនិព្វាន ឥតមានសេចក្ដីទុក្ខ មានត្រឹមតែបរមសុខ ឥតទុក្ខសូម្បីបន្តិចបន្តួចលាយឡំឡើយ។ ទោះបីយើងមិនចង់ត្រាស់ជាព្រះពុទ្ធក៏ដោយ ឲ្យតែយើងប្រតិបត្តិតាមគោលការណ៍នេះ ក៏គង់នឹងបានដល់និព្វានក្នុងឋានៈជាសាវកឬសាវិកាដែរ។ មុននឹងបានសម្រេចនិព្វាន ប្រាកដជានឹងបានឋានៈជាមហាបុរសឬវីរបុរសក្នុងលោកពុំខាន។

ចប់

# ពុទ្ធភាសិត

បុគ្គលណា មិនធ្វើបាបកម្មព្រោះហេតុនៃខ្លួននិងអ្នកដទៃទេ, មិនចង់បាននូវកូន ទ្រព្យនិងដែន ដោយវិធីធ្វើបាបកម្មទេ, មិនចង់បាននូវសមិទ្ធិដើម្បីខ្លួន ដោយអយុត្តិធម៌ទេ, បើទុកជាចង់បាន ក៏មិនព្រមធ្វើបាបកម្ម បុគ្គលនោះឈ្មោះថា ជាអ្នកមានសីល ជាអ្នកមានប្រាជ្ញា ជាអ្នកឋិតនៅក្នុងធម៌។

ធម្មបទដ្ឋកថា បណ្ឌិតវគ្គ

ស្រាវជ្រាវដោយៈ ថាច់ សុតឹម